# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការសាលាឧទ្ធរណ៍
លេខ ៥៤៨/២០០១

## អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

**ជម្រាបមក**

**លោក ព្រះរាជអាជ្ញាតុលាការគ្រប់ ខេត្ត ក្រុង**

**កម្មវត្ថុ:** ការចូលរួមបង្ក្រាបបទល្មើសលួចកាប់ឈើ តាមបណ្តាខេត្ត-ក្រុង នានានៃព្រះរាជាណាចក្រកម្ពុជា ។
**យោង:** លិខិតលេខ ១៦៣០ រ.ប្រ កដរបព ចុះថ្ងៃទី២៣-០៨-២០០១ របស់នាយកដ្ឋានរុក្ខាប្រមាញ់ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាគ្រប់ ខេត្ត-ក្រុង ថា នាពេលបច្ចុប្បន្ននៅតាមបណ្តាខេត្ត-ក្រុងនានានៃព្រះរាជាណាចក្រកម្ពុជានៅតែកើតមានការលួចកាប់ឈើជាច្រើនកន្លែង ដែលតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលត្រូវបំបាត់ឱ្យអស់ជាស្ថាពរ ដើម្បីបំពេញកិច្ចការនេះនាយកដ្ឋានរុក្ខាប្រមាញ់នៃក្រសួងកសិកម្មបានសុំឱ្យមានការចូលរួមពីព្រះរាជអាជ្ញាក្នុងប្រតិបត្តិការចុះបង្ក្រាបបទល្មើសព្រៃឈើឱ្យមានប្រសិទ្ធិភាពខ្ពស់

យោងតាមបញ្ញត្តិមាត្រា ៣៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ព្រះរាជអាជ្ញា ខេត្ត-ក្រុង បំពេញមុខងារជាអ្នកដឹកនាំផ្ទាល់រាល់ប្រតិបត្តិការបង្ក្រាបបទល្មើសទាំងឡាយរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងរង្វង់ដែនដីសមត្ថកិច្ចរបស់ខ្លួន ។

អាស្រ័យហេតុដូចបានជម្រាបមកខាងលើ សូមលោកព្រះរាជអាជ្ញាតាមបណ្តា ខេត្ត-ក្រុង ចូលរួមបង្ក្រាបបទល្មើសលួចកាប់ឈើដែលកើតមានក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន តាមសំណូមពររបស់នាយកដ្ឋានរុក្ខាប្រមាញ់តទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១

**អគ្គព្រះរាជអាជ្ញារង**

**គង់ ស្រ៊ីម**

<u>ចម្លងជូន</u>
-នាយកដ្ឋានរុក្ខាប្រមាញ់.....០១ច្បាប់
-ដើម្បីជ្រាប